# ព្រះរាជក្រឹត្យ

នស/រកត/០៧០៩/៧៤៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣៩៣ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងមន្ត្រីរាជការឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ចំនួន ៧ រូប ដូចមានរាយនាមខាងក្រោម:

១- ឯកឧត្តម **កៅ គឹមហួន** ជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *រដ្ឋមន្ត្រី* បន្ថែមលើមុខងារបច្ចុប្បន្ន

២- ឯកឧត្តម **សុខ សារ៉ាវុឌ្ឍ** ជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *អនុរដ្ឋលេខាធិការ* បន្ថែមលើមុខងារបច្ចុប្បន្ន

៣- ឯកឧត្តម **ហាវ រតនៈ** ជាអគ្គលេខាធិការរងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *អនុរដ្ឋលេខាធិការ* បន្ថែមលើមុខងារបច្ចុប្បន្ន

Downloaded from http://www.khmerlaws.com

៤- ឯកឧត្តម **អ៊ុង លុយណា** ជាប្រធានផ្នែកសិក្សា និងវិភាគគោលនយោបាយសង្គមកិច្ច នៃអគ្គលេខាធិការដ្ឋាន ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *អគ្គនាយក* បន្ថែមលើមុខងារបច្ចុប្បន្ន

៥- ឯកឧត្តម **ជា វុធណា** ជាជំនួយការ ឯកឧត្តមប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *អគ្គនាយក* បន្ថែមលើមុខងារបច្ចុប្បន្ន

៦- ឯកឧត្តម **អ៊ុយ សារិន** ជាជំនួយការ ឯកឧត្តមប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *អគ្គនាយក* បន្ថែមលើមុខងារបច្ចុប្បន្ន

៧- ឯកឧត្តម **ថេង បញ្ញាធន** ជាជំនួយការ ឯកឧត្តម **ទួន ថាវរៈ** សមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *អគ្គនាយក* បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២:** តម្លើងឋានៈស្មើ *អគ្គនាយក* ជូនឯកឧត្តម **ជុំ វណ្ណៈ** ជំនួយការឯកឧត្តម **សុន គន្ធា** អនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ។

**មាត្រា ៣:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចស.ល. ០៩០៧. ៧៣៦

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៩*

លេខ: ៦៤៤. ច.ល

បានឃើញ និងបញ្ជូនចែក

រាជធានីភ្នំពេញ, ថ្ងៃទី ... ខែកក្កដា ឆ្នាំ២០០

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃួន ជិនកេន

Downloaded from http://www.khmerlaws.com